Cambodian
Women's
Crisis
Center

# ជួយស្ត្រីដើម្បីអោយស្ត្រីជួយខ្លួនឯង

# របាយការណ៍ប្រចាំឆ្នាំ



២០២៥

# សេចក្តីផ្តើម

បើទោះជាមានយន្តការជាតិនិងយន្តការទាំងឡាយ ត្រូវបានដាក់ឲ្យអនុវត្តន៍ ដើម្បីលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជាយ៉ាងណាក៏ដោយ សមភាពយេនឌ័រនៅកម្ពុជានៅមិនទាន់ទទួលបានភាពស្មើគ្នាគ្រប់ជ្រុងជ្រោយទាំងស្រុងនោះទេ ទោះបីជាមានការខិតខំប្រឹងប្រែងរួមគ្នាពីស្ថាប័នរាជរដ្ឋាភិបាល និងសង្គមស៊ីវិលនានាក៏ដោយ។ ស្ត្រីភាគច្រើនដែលរស់នៅទីជនបទដាច់ស្រយាល ជាពិសេសក្រុមស្ត្រីដែលមានចំនួនតិចនៅក្នុងសង្គមមិនទាន់ទទួលបាននូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួននោះពេញលេញនៅឡើយទេ ដោយស្ត្រីនិងក្មេងស្រីទាំងនោះ មិនទទួលបាននូវភាពស្មើគ្នាក្នុងការទទួលសេវាថែទាំសុខភាព ការអប់រំ អាជីពការងារ និងការចូលរួមផ្នែកនយោបាយ។ មួយវិញទៀត អំពើហិង្សាក៏បាននឹងកំពុងកើតមានឡើងជារៀងរាល់ថ្ងៃ ដែលបង្កឲ្យមានអស្ថេរភាពក្នុងគ្រួសារ ភាពក្រីក្រ និងការធ្លាក់ចុះនូវធនធានមនុស្ស។ កត្តាទាំងនេះបានជះឥទ្ធិពល មិនល្អមកលើប្រជាជនជាច្រើន ជាពិសេសគឺស្ត្រី ដែលធ្វើឲ្យពួកគេពុំអាចប្រើប្រាស់សិទ្ធិមនុស្សជាសកលរបស់ខ្លួនបាន។

អង្គការ CWCC បាននឹងកំពុងធ្វើការយ៉ាងជិតស្និត ជាមួយម្ចាស់ជំនួយដោយទទួលបានការគាំទ្រ និងការគិតគូរអំពីបំលាស់ប្តូរនិន្នាការនៅក្នុងការផ្តល់មូលនិធិរបស់ម្ចាស់ជំនួយ។ ជាមួយគ្នានេះដែរ អង្គការ CWCC បានបង្កើនកិច្ចសហការជាមួយស្ថាប័នរដ្ឋារាជភិបាល ដៃគូរអភិវឌ្ឍន៍ សង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធ ដែលជាយន្តការមួយក្នុងការផ្តល់ការគាំទ្រ និងអន្តរាគមដ៏មានប្រសិទ្ធិភាព ដែលជាកម្លាំងចលករក្នុងការជំរុញធ្វើឲ្យប្រសើរឡើងនូវសមភាពយេនឌ័រនៅកម្ពុជា។

អង្គការ CWCC ផ្តោតការយកចិត្តទុកដាក់ក្នុងការធ្វើអន្តរាគមន៍ និងផ្តល់សេវាដើម្បីកាត់បន្ថយអំពើហិង្សា និងពង្រឹងសិទ្ធអំណាចដល់ស្ត្រី ជាពិសេសពាក់ព័ន្ធនឹងបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ និងការជួញដូរផ្លូវភេទ ការជួញដូរស្ត្រី និងកុមារ និងការទទួលបានភាពស្មើគ្នារបស់ក្មេងស្ត្រីក្នុងវិស័យអប់រំ ។

## វិធីសាស្ត្ររបស់អង្គការ



**តំបន់គោលដៅរបស់អង្គការ**

- រាជធានីភ្នំពេញ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តសៀមរាប៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តបន្ទាយមានជ័យ៖ ការិយាល័យប្រចាំតំបន់ និង មណ្ឌលសុវត្ថិភាព
- ខេត្តកំពង់ធំ៖ ការិយាល័យប្រចាំតំបន់
- ខេត្តកំពង់ស្ពឺ៖ បណ្តាញគោលដៅ

**ទស្សនវិស័យ**

ស្ត្រី និងកុមារី រស់នៅដោយសន្តិភាព សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ហើយរីករាយនឹងសិទ្ធិមនុស្សជាសកលរបស់ខ្លួន។

**បេសកម្ម**

ពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីឲ្យទាមទារសិទ្ធិជាសកលរបស់ខ្លួន ដើម្បីទទួលបាននូវសុវត្ថិភាពផ្ទាល់ខ្លួន និងចូលរួមដោយស្មើភាពគ្នាក្នុងការងារសហគមន៍ សង្គមស៊ីវិល ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងចូលរួមក្នុងសកម្មភាពនយោបាយ សង្គម និងវប្បធម៌។

**ទិសដៅរួម**

ចូលរួមពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារីដែលរងគ្រោះ និងងាយរងគ្រោះ តាមរយៈការទប់ស្កាត់ ការការពារ និងការតស៊ូមតិ ដើម្បីលើកកម្ពស់ឲ្យមានសង្គមមួយដែលមាន សន្តិភាព សមភាពយេនឌ័រ និងក្តីមេត្តា ករុណា។

**តម្លៃស្នូល**

**សេចក្តីថ្លៃថ្នូរ៖** មនុស្សគ្រប់រូប ដោយមិនគិតពីឋានៈ ភេទ អសមត្ថភាព និងភាពខុសប្លែកដទៃទៀត គឺត្រូវរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

**ភាពយុត្តិធម៌៖** មនុស្សគ្រប់រូប គួរតែរីករាយ និងទទួលបាននូវសិទ្ធិស្មើគ្នា នៅក្នុងការចូលរួមនៅក្នុងកិច្ចការនយោបាយ និងការអនុវត្ត ដែលអាចទទួលបាននូវការបែងចែកអំណាច ធនធាន និងឱកាសស្មើៗគ្នា។

**គណនេយ្យភាព៖** ធនធាន និងការទទួលខុសត្រូវ សម្រាប់ធ្វើការសម្រេចចិត្ត ត្រូវបានប្រើប្រាស់ជាមធ្យោបាយមួយ សម្រាប់ធ្វើឲ្យមានតម្លាភាព និងអាចឆ្លើយតបទៅនឹងម្ចាស់ជំនួយ ដែលស្របតាមធម្មនុញ្ញភាព ព្រមទាំងបំពេញតម្រូវការសហគមន៍។

**កម្មវិធីរបស់អង្គការ**

គោលដៅរួមរបស់អង្គការនឹងត្រូវបានសម្រេចឡើងតាមរយៈកម្មវិធីយុទ្ធសាស្ត្រចំនួនបួន៖

យុទ្ធសាស្ត្រទី១: កម្មវិធីទប់ស្កាត់

យុទ្ធសាស្ត្រទី២: កម្មវិធីការពារ

យុទ្ធសាស្ត្រទី៣: កម្មវិធីស្វែងរកមតិគាំទ្រ

យុទ្ធសាស្ត្រទី៤: ការអភិវឌ្ឍន៍អង្គការ

## ១. កម្មវិធីទប់ស្កាត់

### ១.១ គម្រោងរៀបចំសហគមន៍

ការអប់រំ និងពង្រឹងសិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងសហគមន៍ មន្ត្រីមានកាតព្វកិច្ច អ្នកដឹកនាំសហគមន៍ និងអាណាព្យាបាល ដើម្បីផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគាត់ទាក់ទងនឹងសិទ្ធិស្ត្រី និងកុមារ គឺជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រផ្សេងៗទៀតរបស់អង្គការ CWCC ក្នុងការដោះស្រាយបញ្ហាអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។ គម្រោងរៀបចំសហគមន៍បានផ្តល់ការកសាងសមត្ថភាពដល់មន្ត្រីមានកាតព្វកិច្ចដែលរួមមាន អ្នកដឹកនាំសហគមន៍ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីប៉ូលីស អំពីសិទ្ធិស្ត្រី សិទ្ធិរបស់ជនមានពិការភាព អំពើហិង្សាទាក់ទងយេនឌ័រ ច្បាប់អំពើហិង្សាក្នុងគ្រួសារ ច្បាប់ប្រឆាំងការជួញដូរ និងលើកកំពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

តាមរយៈកិច្ចសហការជាមួយមន្ទីរកិច្ចការនារីខេត្តគោលដៅគម្រោង បានបង្កើតនិងដំណើរការក្រុមការងារឆ្លើយតបអំពើហិង្សាទាក់ទងយេនឌ័រចំនួន២ក្រុម ក្នុងស្រុកសាមគ្គីមុនីជ័យ ក្នុងខេត្ត កំពង់ស្ពឺ និង ស្រុកស្វាយលើក្នុងខេត្តសៀមរាប ដែលមានសមាជិកសរុបចំនួន ៦៤ នាក់ (ស្ត្រី៥២នាក់)។ ក្នុងឆ្នាំ២០២៥គម្រោងបានបន្តធ្វើការដោយផ្ទាល់ជាមួយក្រុមគាំទ្រស្ត្រី និងយុវជនចំនួន៨ក្រុមដែលមានសមាជិកចំនួន១៣៥នាក់ (ស្រី១០៦) និងក្រុមទាំងអស់បានដើរតួរនាទីជាភ្នាក់ងារសម្រាប់ធ្វើអោយមានការផ្លាស់ប្តូរនៅក្នុងសហគមន៍របស់ពួកគេរៀងៗខ្លួន តាមរយៈ ការលើកកំពស់ការយល់ដឹង ទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ប្រមាណជា ៣,០៧៤នាក់ (ស្រី២,០៥៣) ពិការភាពចំនួន៨២នាក់ ដែលក្នុងនោះ (៦៧%)ជាស្ត្រី ។

### ១.២ បញ្ចប់ការដាក់ទណ្ឌកម្មលើកុមារ និងការលើកកម្ពស់ការចិញ្ចឹមកូនបែបវិជ្ជមាន

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានសហការជាមួយមន្ទីរកិច្ចការនារី និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងខេត្តគោលដៅទាំងបី ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង បានរៀបចំវគ្គបណ្តុះបណ្តាល រំលឹកស្តីពីការការពារកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមានសម្រាប់សមាជិកគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ (គកនក) ឃុំ សង្កាត់ ចំនួន ៦៩នាក់ ក្នុងនោះស្រីចំនួន ៤៧នាក់។

**វគ្គបណ្តុះបណ្តាលនេះ ផ្តោតទៅលើចំណុចសំខាន់ៗចំនួន៣៖**

- ពង្រឹងសមត្ថភាពរបស់ គកនក ក្នុងការការពារកុមារ និងការចិញ្ចឹមកូនបែបវិជ្ជមាន។
- ជាគ្រូបង្គោលដើម្បីបណ្តុះបណ្តាលបន្តដល់ក្រុមឪពុកម្តាយគំរូនិងក្រុមជួយខ្លួនឯង ទៅលើប្រធានបទ "ការចិញ្ចឹម កូនបែបវិជ្ជមាន" និងធ្វើការផ្សព្វផ្សាយបន្តអំពីការចិញ្ចឹមកូនបែបវិជ្ជមាននៅក្នុងសហគមន៍របស់ពួកគេ។
- ពង្រឹងសមត្ថភាពដល់គកនក ក្នុងការសហការលើការការពារ ការអន្តរាគមន៍ ការផ្តល់សេវា និងការឆ្លើយតប ចំពោះកុមារងាយរងគ្រោះដែលរងផលប៉ះពាល់ដោយអំពើហិង្សាការប្រើប្រាស់សារធាតុញៀន និងការរំលោភ សិទ្ធិកុមារ។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានសហការជាមួយក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើដំណើរទស្សនកិច្ចត្រួតពិនិត្យ ដែលមាន គោលបំណងវាយ

តម្លៃវឌ្ឍនភាពក្នុងការអនុវត្តការបណ្តុះបណ្តាល និងសកម្មភាពលើកកម្ពស់ការយល់ដឹង អំពីការការពារកុមារ និងការអនុវត្តការចិញ្ចឹម កូនបែបវិជ្ជមានក្នុងចំណោមឪពុកម្តាយ អាណាព្យាបាល និងឪពុកម្តាយនៅកម្រិតសហគមន៍។ ការវាយតម្លៃបានឆ្លុះបញ្ចាំងពីចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាលអ្នកសម្របសម្រួលសំខាន់ៗដែលបានធ្វើឡើងក្នុងខែតុលា ឆ្នាំ២០២៤ ដែលផ្តោតលើសារៈសំខាន់នៃវិធីសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន ការការពារកុមារ ផលប៉ះពាល់នៃអំពើហិង្សាលើកុមារ ទម្រង់នៃការដាក់ទណ្ឌកម្មរាងកាយ និងផ្លូវចិត្ត សិទ្ធិកុមារ និងក្របខ័ណ្ឌច្បាប់ដែល ការពារកុមារពីអំពើហិង្សានៅក្នុងប្រទេសកម្ពុជា។ ដំណើរទស្សនកិច្ចនេះ ក៏បានវាយតម្លៃពីការអនុវត្តទាំងនេះត្រូវបានអនុវត្ត ប្រកបដោយប្រសិទ្ធភាព និងផលប៉ះពាល់របស់វានៅក្នុងសហគមន៍។ ក្នុងអំឡុងពេលទស្សនកិច្ច ការពិភាក្សាជាក្រុមបាន វាយតម្លៃការអនុវត្តការការពារកុមារ និងការអនុវត្តការចិញ្ចឹម កូនបែបវិជ្ជមានក្នុងចំណោមសមាជិកសហគមន៍ និងក្រុមឪពុកម្តាយ(PIGs) នៅក្នុងឃុំគោលដៅ។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ សហការជាមួយ មន្ទីរអប់រំយុវជន និងកីឡាខេត្ត(DoEYS) និងការិយា ល័យអប់រំ យុវជន និងកីឡា បានរៀបចំ វគ្គបណ្តុះបណ្តាលរំលឹកដល់នាយកសាលា និងគណៈកម្មការ គ្រប់គ្រងសាលារៀន (SMCs) ដោយមានសិក្ខាកាមចំនួន ៧៤ នាក់ (ស្រី១៥ នាក់) លើប្រធានបទ សំខាន់ៗដូចជា៖ អំពើហិង្សាលើកុមារ ការដាក់ទណ្ឌកម្មលើរាងកាយ ការដាក់វិន័យវិជ្ជមាន សិទ្ធិកុមារ ការការពារកុមារ ការប្រើប្រាស់គ្រឿងញៀន និងចំណេះដឹងក្នុងការរាយការណ៍ករណីអំពើហិង្សាលើកុមារ ។ នាយកសាលាដែលទទួលបានការបណ្តុះបណ្តាល ពីគ្រូបង្គោលមកពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡា បានធ្វើការផ្សព្វផ្សាយបន្តដល់ លោកគ្រូអ្នកគ្រូនៅក្នុងសាលាគោលដៅ ដែលសកម្មភាពនេះដឹកនាំដោយនាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលា ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងចំណោមគ្រូបង្រៀនអំពីវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព។ បន្ទាប់ពី ការបណ្តុះបណ្តាល នាយកសាលា និងសមាជិកគណៈកម្មការគ្រប់គ្រងសាលា បានធ្វើការលើកកម្ពស់ការ យល់ដឹងចំនួន១២៩ដង ទៅដល់គ្រូបង្រៀនចំនួន ២៣៦០ នាក់ (ស្រី១៣៤២ នាក់) ទៅលើអំពើ ហិង្សាលើកុមារ ការដាក់ទណ្ឌកម្មលើរាងកាយ ការដាក់វិន័យវិជ្ជមាន សិទ្ធិកុមារ ការការពារកុមារ ការប្រើប្រាស់ គ្រឿងញៀន និងរបៀបរាយការណ៍ករណី អំពើហិង្សាលើ កុមារនៅក្នុងសាលា។

ដោយមានកិច្ចសហប្រតិបត្តិការពីក្រសួងអប់រំយុវជន និងកីឡា និងសម្របសម្រួលដោយ CWCC, COCD និង VCAO ដំណើរទស្សនកិច្ចត្រួតពិនិត្យមួយត្រូវបានធ្វើឡើងជាមួយសាលារៀនចំនួនប្រាំមួយនៅក្នុង ឃុំចំនួនប្រាំនៅទូទាំង ខេត្តគោលដៅចំនួនបី។ គោលបំណងនៃដំណើរទស្សនកិច្ចនេះគឺដើម្បីវាយតម្លៃវឌ្ឍនភាព នៃការអនុវត្តវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពនៅតាមសាលារៀន កំណត់ តម្រូវការ ចំណុចខ្លាំង បញ្ហាប្រឈម និងការគាំទ្រដើម្បីកែលម្អការអនុវត្ត ចែករំលែកការអនុវត្តល្អ និងប្រមូលមតិយោបល់ និងពង្រឹងកិច្ចសហការរវាង ក្រសួងអប់រំយុវជន និងកីឡា និងអ្នកពាក់ព័ន្ធថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធភាព។

ក្នុងឆ្នាំ២០២៥ បុគ្គលិកគម្រោងនៃអង្គការ បានសម្របសម្រួលជាមួយសមាជិកនៃគណៈកម្មាធិការទទួលបន្ទុក កិច្ចការនារី និងកុមារឃុំ ក្នុងស្រុកគោលដៅ ដើម្បីធ្វើការលើកកម្ពស់ការយល់ដឹងសម្រាប់ឪពុក

ម្តាយ/អ្នកថែទាំ នៅក្នុង សហគមន៍សរុបចំនួន៦៦៨ដង ដែលមានអ្នកចូលរួមសរុប ១៧០៦៧ នាក់ក្នុងនោះ ១២០៧៥នាក់ជាស្ត្រី បានចូលរួម ក្នុងការអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងការចិញ្ចឹមកូនបែបវិជ្ជមាន។ ការអប់រំផ្សព្វផ្សាយ ទាំងនេះផ្តោតលើប្រធាន បទសំខាន់ៗដូចជា៖ ការការពារកុមារ ការចិញ្ចឹមកូនបែបវិជ្ជមាន ការគ្រប់គ្រងកំហឹង ការប្រើប្រាស់គ្រឿងញៀន សិទ្ធិកុមារ និងនីតិវិធីរាយការណ៍ករណី។

មន្ត្រីគម្រោងបានសម្របសម្រួលក្រុមឪពុកម្តាយគំរូ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសចំនួន ៩២ដង ដោយមានអ្នកចូលរួមសរុបចំនួន ៣១០ នាក់ (ស្រី ២៣០ នាក់)។ កិច្ចប្រជុំទាំងនេះផ្តោតលើការបង្កើត គោលការណ៏ក្រុម ពិភាក្សាអំពីផែនការសកម្មភាព និង ចែករំលែកបទពិសោធន៍ពីការចិញ្ចឹមកូនបែបវិជ្ជមាន ជាមួយ សមាជិកក្រុម។

អង្គការដៃទាំង៣ បានសហការជាមួយ គណៈកម្មការគ្រប់គ្រងសាលា(SMCs) និង គកនក បានផ្តល់សម្ភារៈសិក្សាដល់ក្លឹបកុមារ។ សិស្សសរុបចំនួន ២៧០ នាក់ (ស្រី ១៨៩ នាក់) គឺជាសមាជិកនៃក្លឹបកុមារ។ សិស្សម្នាក់ៗទទួលបានសម្ភារសិក្សារួមមាន កាបូបស្ពាយមួយ សៀវភៅចំនួន២៧ក្បាល ប៊ិចក្រហមនិងខៀវចំនួន២០ដើម ផ្លាស់ស្ទិចកសារចំនួន២ និងកាបូបដាក់ប៊ិច១។ បន្ថែមពីនេះ សមាជិកក្លឹបចំនួន៨១នាក់ (ស្រី៥៧នាក់) ក្នុងចំណោមសមាជិកក្លឹប ចំនួន២៧០នាក់ មកពីគ្រួសារក្រីក្រកម្រិត ១ និងកម្រិត ២ ទទួលបានកង់១នាក់ ចំនួន១គ្រឿង។

ក្លឹបកុមារចំនួន១៨ក្លឹប ដែលក្លឹបនីមួយៗបានបែងចែកជាក្រុមតូចៗចំនួន៥៤ក្រុម ក្នុង១ក្រុមមាន សមាជិកចំនួន ៥នាក់ ដែលស្មើនឹងមានសមាជិកសរុបចំនួន ២៧០នាក់ បានធ្វើការអប់រំផ្សព្វផ្សាយចំនួន ២១៤វគ្គ ដល់អ្នកចូលរួម សរុបចំនួន៩៥៨២នាក់ (ក្មេងស្រី ៥៤១៩ នាក់) នៅក្នុងសាលារៀន និងសហគមន៍។ ការផ្សព្វផ្សាយនេះផ្តោតលើប្រធាន បទសំខាន់ៗដូចជា៖ អំពើហិង្សាលើកុមារ ការដោះស្រាយជម្លោះអហិង្សា ការដាក់ទណ្ឌកម្មលើរាងកាយ សិទ្ធិកុមារ ការការពារកុមារ ការប្រើប្រាស់គ្រឿងញៀន និងរបៀបរាយការណ៍ អំពីអំពើហិង្សា និងការស្វែងរកនូវសេវាគាំទ្រចាំបាច់ នានា។

មន្ត្រីគម្រោងបានសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសចំនួន៩០ដង សម្រាប់ក្លឹបកុមារចំនួន ១៨ ដែលមានសិស្សចូលរួមសរុបចំនួន២៩៧នាក់(ស្រី២០២នាក់)។ កិច្ចប្រជុំបានផ្តោតជាសំខាន់លើការពិនិត្យឡើងវិញនូវគោល ការណ៏ក្រុម តួនាទី និងការទទួលខុសត្រូវ ផែនការសកម្មភាព និងរបៀបដោះស្រាយបញ្ហាប្រឈមក្នុងអំឡុងពេលអនុវត្ត សកម្មភាពផ្សព្វផ្សាយអប់រំ។

តំណាងក្លឹបកុមារបានចែករំលែកការចូលរួមរបស់ពួកគេក្នុងពិធីប្រកាសជាផ្លូវការនៃផែនការសកម្មភាពជាតិដើម្បីបង្ការ និងឆ្លើយតបនឹងអំពើហិង្សាប្រឆាំងនឹងកុមារ ឆ្នាំ ២០២៥-២០៣០ (NAPVAC)។ តាមរយៈការកិច្ចប្រជុំប្រចាំ ត្រីមាននេះ កុមារបានចូលរួមចំណែកក្នុងការផ្សព្វផ្សាយផែនការជាតិ លើកកម្ពស់ការចូលរួមរបស់កុមារក្នុងនាមជា ម្ចាស់ សិទ្ធិ និងគាំទ្រដល់ការចូលរួមរបស់កុមារកាន់តែច្រើនក្នុងការអភិវឌ្ឍ និងការអនុវត្តច្បាប់ និងគោលនយោបាយទាក់ទងនឹងកុមារ។

ក្រុមការងារគម្រោងបានបើកវគ្គបណ្តុះបណ្តាលរំលឹករយៈពេលមួយថ្ងៃស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុនិង ការគ្រប់គ្រង ក្រុមសម្រាប់គណៈកម្មការ និងសមាជិកនៃក្រុមជួយខ្លួនឯងចំនួន ៧២នាក់។ វគ្គបណ្តុះបណ្តាល

នេះមានគោលបំណង ផ្តល់ចំណេះដឹងលើការគ្រប់គ្រងហិរញ្ញវត្ថុក៏ដូចជាការកសាងភាពជាអ្នកដឹកនាំនិងជំនាញសម្របសម្រួល។ ក្រុមការងាររបស់គម្រោងបានសម្របសម្រួលការប្រជុំសមាជិកក្រុមជួយខ្លួនឯងប្រចាំខែចំនួន១៧៥ដង ដែលមានអ្នកចូលរួមសរុបចំនួន ២៥២នាក់ជាស្ត្រី។ តាមរយៈកិច្ចប្រជុំនេះ សមាជិកក្រុមជួយខ្លួនឯងទទួល បានការយល់ដឹង កាន់តែច្បាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ដោយសម្រួលដល់សមាជិក ទាំងអស់ឱ្យចាប់ផ្តើមដំណើរ ការសន្សំ និងធ្វើឱ្យពួកគេដឹងពីផែនការបន្ទាប់សម្រាប់ក្រុម។

អង្គការទាំង៣ សហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ (គកនក) បានផ្តល់ការ លើកកម្ពស់ការយល់ដឹងចំនួន៦៦ដង ជាមួយក្រុមស្ត្រីជួយខ្លួនឯង (SHGs) ចំនួន ៦៣៤ នាក់។ វគ្គទាំងនេះផ្តោតលើការ ចិញ្ចឹមកូនបែបវិជ្ជមាន ការបង្ការអំពើហិង្សា និងការការពារកុមារ។ បន្ថែមពីនេះ វគ្គទាំងនេះបានជួយអ្នកចូលរួមឱ្យយល់ អំពីការការពារកុមារ និងរបៀបរាយការណ៍ករណី។

ក្នុងឆ្នាំ២០២៥ អង្គការដៃគូគម្រោងទាំងអស់បានសហការជាមួយពេទ្យសត្វភូមិដើម្បីចុះតាមដានពីការចិញ្ចឹមសត្វ និងការប្រើប្រាស់ចំណេះដឹងដែលបានរៀនកន្លងមកបានចំនួន ៩៧ដង ក្នុងគោលបំណងផ្តល់ការណែនាំផ្នែកបច្ចេកទេស តាមដានវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈមនានាដែលសមាជិកនៃក្រុមជួយខ្លួនឯង (SHGs) ជួបប្រទះ ដែលភាគច្រើនជាស្ត្រីដែលចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូលដូចជាការចិញ្ចឹមសត្វ ការលក់ដូរខ្នាតតូច និងការដាំដុះបន្លែ។ ជាលទ្ធផល ពេទ្យសត្វបានផ្តល់ការគាំទ្រលើការចាក់វ៉ាក់សាំងសត្វពាហនៈ ការលាយចំណី អនាម័យ និងការអនុវត្តការថែទាំ។

**១.៣ គម្រោងលើកកម្ពស់ការអប់រំរបស់ក្មេងស្រី**

គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់កុមារីងាយរងគ្រោះ ដែលក្នុងនោះរួមមាន កុមារីមកពីគ្រួសារក្រីក្រ កុមារីដែលមានអំពើហិង្សាក្នុងគ្រួសារ និងកុមារីដែលប្រឈមមុខនឹងការបោះបង់ចោលការសិក្សានៅក្នុងតំបន់គោលដៅនៃខេត្តសៀមរាបនិងរាជធានីភ្នំពេញ។ ក្នុងឆ្នាំ២០២៥ គម្រោងបានផ្តល់កញ្ចប់អាហារូបករណ៍ទៅដល់ក្មេងស្រីចំនួន២០០នាក់ ចាប់ពីកំរិតអនុវិទ្យាល័យ ដល់កំរិតវិទ្យាល័យ (ក្មេងស្រី ១០០នាក់ក្នុងខេត្តសៀមរាប និង ១០០នាក់ក្នុងរាជធានីភ្នំពេញ) ។ គម្រោងបានធ្វើការសហការណ៍ជាមួយក្រុមការងារអប់រំថ្នាក់មូលដ្ឋាន និង ក្រុមសម្របសម្រួលថ្នាក់ស្រុកក្នុងការជ្រើសរើសក្មេងស្រីអាហារូបករណ៍ និងផ្តល់កញ្ចប់អាហារូបករណ៍ ដើម្បីគាំទ្រការសិក្សារបស់ពួកគេ ។ កញ្ចប់អាហារូបករណ៍ដែលគម្រោងបានផ្តល់ជូនរួមមាន សម្ភារៈសិក្សា ឯកសណ្ឋានសិស្ស កង់ ប្រាក់ឧបត្ថម្ភប្រចាំខែ ប្រាក់សម្រាប់រៀនគួរក្រៅម៉ោង វគ្គបណ្តុះបណ្តាលកំព្យូទ័រ និងភាសាអង់គ្លេស។ ការផ្តល់ជូនទាំងនេះបានជួយ សម្រួលអោយក្មេងស្រីបន្តការសិក្សា និងទៅរៀនបានទៀងទាត់ ។ ក្មេងស្រីដែលមកពីគ្រួសារក្រីក្រ អាចមានលទ្ធភាពក្នុងការរៀនសូត្រ និងបន្តការសិក្សារបស់ខ្លួនទៅកាន់វគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ តាមរយៈកញ្ចប់អាហារូបករណ៍ និងបណ្តាញរបស់គម្រោងជាមួយសាលាជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈនានា ។ ក្នុងឆ្នាំសិក្សា២០២៤-២០២៥ គម្រោងមានសិស្សសរុបចំនួន ១៣១នាក់ ដែលរៀនថ្នាក់ទី១២ បានចូលរួមប្រឡងមធ្យមសិក្សាទុតិយភូមិ នៅក្នុងខេត្តសៀមរាប និងរាជធានីភ្នំពេញ ក្នុងនោះមានសិស្ស ១០០ នាក់នៅសៀមរាប និង ៣១នាក់នៅរាជធានីភ្នំពេញ។ សិស្សចំនួន ១១៦នាក់បានប្រឡងជាប់ (៩២នាក់នៅសៀមរាប និង ៤២នាក់នៅភ្នំពេញ) ។

សិស្សចំនួន៤នាក់ទទួលបានពិន្ទុ A (Excellent) រួមមាន ៣នាក់មកពីខេត្តសៀមរាប និង ១ នាក់មកពីរាជធានីភ្នំពេញ។ សិស្សចំនួន ១០ នាក់ទទួលបានពិន្ទុ B (ល្អណាស់)។ សិស្សចំនួន ៣៣នាក់ទទួលបានពិន្ទុ C (ល្អ)។ សិស្សភាគច្រើនចំនួន ៥២ នាក់ទទួលបានពិន្ទុ D (Fair)។ លើសពីនេះ សិស្សចំនួន ១៧ នាក់ទទួលបានពិន្ទុ E (Pass)

**១.៤ គម្រោងពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រី**

កម្មវិធីពង្រឹងសមត្ថភាពផ្នែកសេដ្ឋកិច្ចដល់ស្ត្រីមានគោលបំណង ផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងក្មេងស្រីដែលរស់នៅក្នុងតំបន់គោលដៅ ដើម្បីអោយពួកគាត់មានជីវភាពរស់នៅល្អប្រសើរ ជាមួយនឹងបណ្តាញសង្គមដ៏រឹងមាំមួយ ដើម្បីជួយអោយពួកគាត់យកឈ្នះលើបញ្ហាហិរញ្ញវត្ថុ និងកាត់បន្ថយភាពងាយរងគ្រោះពីរាល់ទម្រង់នៃអំពើហិង្សា។ ក្នុងឆ្នាំ២០២៥ គម្រោងបានធ្វើការជាមួយក្រុមសន្សំ៨១ក្រុម ដែលក្នុងនោះមាន ៤៥ក្រុមក្នុងខេត្តសៀមរាប ២៤ក្រុមក្នុងខេត្តកំពង់ធំ ១០ក្រុមក្នុងខេត្តបន្ទាយមានជ័យ និង៦ក្រុមក្នុងខេត្តកំពង់ស្ពឺ។ ក្រុមទាំងអស់មាន សមាជិកសរុបចំនួន ២៥២៩នាក់ (ស្ត្រី២២៣២នាក់)។ ក្រៅពីនេះគម្រោងក៏បានបន្តគាំទ្រដល់ក្រុមស្ត្រីធ្វើអាជីវកម្ម និងប្រកបមុខរបបផ្សេងៗ ក្នុងគោលបំណងជួយអោយពួកគាត់មានជំនាញ និងអាចរកប្រាក់ ចំណូលសម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារ ។ បន្ថែមពីនេះទៀត គម្រោងបានសម្របសម្រួលស្ត្រី និងក្មេងស្រីក្នុងសហគមន៍ ក្នុងការចូលរៀនជំនាញបច្ចេកទេស និងវិជ្ជាជីវៈ បានចំនួន ២៨នាក់ទទួលជំនាញ ឆុងកាហ្វេ សាឡន និងកាត់ដេរខោអាវ នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ និងជំនាញសាឡនកាត់ដេរ និងបច្ចេកទេសនៅខេត្តសៀមរាប។ ក្នុងនោះដែរ គម្រោងបានផ្តល់ទុនដល់ក្រុមស្ត្រីក្នុងការចិញ្ចឹមសត្វ និងការបង្កើតជំនួញខ្នាតតូច ចំនួន ២១មានដូចជា ការចិញ្ចឹមមាន់ ចិញ្ចឹមត្រី ចិញ្ចឹមជ្រូក និងការផលិតសាប៊ូលាងចាន។ គម្រោងបានផ្តល់ទុនដក់ក្រុមស្ត្រីដែលបានរៀនមុខជំនាញ ដូចជាឆុងកាហ្វេ សាឡន និងកាត់ដេរ បើកហាងអាជីវកម្មចំនួន៥ហាង ហាងកាហ្វេចំនួន១ ហាងកាត់ដេរចំនួន១ និងហាងសាឡនចំនួន៣

**១.៥ គម្រោងចំណាកស្រុកសុវត្ថិភាព និងទប់ស្កាត់ការជួញដូរមនុស្ស**

គម្រោងបានបន្តធ្វើការជាមួយក្រុមជួយខ្លួនឯងចំនួន៣៩ក្រុម ដែលមានសមាជិកសរុបចំនួន៧៤៨ នាក់ (ស្ត្រីចំនួន ៦២៥នាក់) ដែលក្នុងនោះនៅក្នុងស្រុកគោលដៅចំនួន ក្រុងប៉ោយប៉ែត ស្រុកអូជ្រៅ, ស្រុកម៉ាឡៃ និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ មានចំនួន១៦ក្រុម មានសមាជិក២៧៨នាក់ (ស្ត្រីចំនួន២២៧នាក់) សមាជិកចំនួន៤៦៥នាក់ (ស្ត្រីចំនួន៣៩៨នាក់) ក្នុងស្រុកពួក និងក្រឡាញ់ ខេត្តសៀមរាប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ។ បន្ថែមពីនេះ គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីមានកាតព្វកិច្ចស្តីពី ចំណាកស្រុកសុវត្ថិភាព និងអំពើជួញដូរមនុស្ស បានចំនួន ៥០នាក់ (ស្ត្រីចំនួន២៤នាក់)។ ក្នុងឆ្នាំ២០២៥ ជារួមគម្រោងបានធ្វើការផ្សព្វផ្សាយចំណេះដឹងស្តីពី ការធ្វើចំណាកស្រុកមានសុវត្ថិភាព និង ទប់ស្កាត់ការជួយដូរមនុស្សទៅកាន់ប្រជាជនក្នុងសហគមន៍សរុបចំនួន ៣០២៦នាក់ (ស្ត្រី២៤៦៤នាក់)។

## ២. កម្មវិធីការពារ

### ២.១ គម្រោងលើកកម្ពស់បណ្ដាញសហគមន៍ ដើម្បីការពារស្ត្រីនិងកុមារពីរាល់ទម្រង់នៃអំពើហិង្សា

គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកបណ្តាញចម្រុះថ្នាក់ស្រុក ដែលពួកគាត់សុទ្ធសឹងតែជាមន្រ្តីមកពីការិយាល័យកិច្ចការនារី ការិយាល័យសង្គមកិច្ច គណៈកម្មាការទទួលបន្ទុកស្ត្រីនិងកុមារ បុគ្គលិកមណ្ឌលសុខភាព ប៉ូលីស និង បុគ្គលដែលជាធនធានសហគមន៍ ដែលមានស្រាប់ក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប និងខេត្តកំពង់ធំ។ ជាលទ្ធផលក្រុមបណ្តាញចម្រុះថ្នាក់ស្រុកបានអន្តរាគមន៍និងគាំទ្រស្ត្រី និងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងយេនឌ័របានចំនួន១៦៩ករណី ក្នុងចំណោមករណីទាំងនេះមាន១៦៧ករណីជាករណីអំពើរហិង្សាក្នុងគ្រួសារ និង២ជាករណីរំលោភបំពានផ្លូវភេទ។ ក្នុងនោះ ២៨ករណីលែងលះ ២ករណីរំលោភបំពានផ្លូវភេទបញ្ជូនទៅប៉ូលីស ៦ករណីហិង្សាក្នុងគ្រួសារបញ្ជូនទៅ CWCC និង៣១ករណីករណីហិង្សាក្នុងគ្រួសារកំពុងស្ថិតក្នុងដំណើរការដោះស្រាយ។ តាមរយៈការអន្តរាគមន៍នេះស្ត្រី និងកុមារដែលជាជនរងគ្រោះនៃអំពើហិង្សាបានទទួលសេវាដែលសមស្រប និងឆ្លើយតបទៅតាមតម្រូវការរបស់ ពួកគេ ។

### ២.២ គម្រោងជំនួយផ្នែកច្បាប់

ក្នុងឆ្នាំ ២០២៥ មានករណីអំពើហិង្សាទាក់ទងយេនឌ័រចំនួន ៤៥៦ករណី (៦ករណីមានពិការភាព) បានទទួលសេវាកម្មពីការិយាល័យអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និង ខេត្តកំពង់ធំ ។ ក្នុងចំណោមករណីទាំងនោះ មាន២១៧ជាករណីអំពើហិង្សាក្នុងគ្រួសារ ៨៤ជាករណីរំលោភបំពានផ្លូវភេទ និង ១៥៥ជាករណីជួញដូរមនុស្ស ។

**ទិន្នន័យករណីអំពើហិង្សាទាក់ទងយេនឌ័រ ឆ្នាំ ២០២៥**

| ករណី | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ២៨ | ២៦ | ១០៨ | ៥៥ | **២១៧** |
| ការរំលោភបំពានផ្លូវភេទ | ១៤ | ២៨ | ២១ | ២១ | **៨៤** |
| ការជួញដូរមនុស្ស | ១៤៦ | ៩ | ០ | ០ | **១៥៥** |
| **សរុប** | **១៨៨** | **៦៣** | **១២៩** | **៧៦** | **៤៥៦** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

សម្រាប់ដំណើរការនៃការទទួលករណី ៥៩%នៃជនរងគ្រោះមកទទួលសេវាពីអង្គការ CWCC ដោយខ្លួនឯង និ៣៨%ត្រូវបានបញ្ជូនមកកាន់អង្គការ ។ ៤%ត្រូវបានជួយសង្គ្រោះ ដោយមានការចូលរួមពីអង្គការ CWCC ។

## ភាគរយនៃចំនួនអតិថិជនដែលមកទទួលសេវាពីអង្គការ CWCC ឆ្នាំ២០២៥




គម្រោងជំនួយផ្នែកច្បាប់បានផ្តល់ការប្រឹក្សាផ្នែកច្បាប់ និងគាំទ្រជនរងគ្រោះដែលសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅកាន់តុលាការ តាមរយៈការជួយបំពេញឯកសារពត៌មានពាក្យបណ្តឹង និងស្វែងរកភស្តុតាងនានាដូចជាការសម្របសម្រួលក្នុងការធ្វើកោសល្យវិច្ច័យនៅមន្ទីរពេទ្យ។ ក្នុងចំណោមជនរងគ្រោះទាំងអស់ដែលមកស្វែងរកជំនួយពីអង្គការ CWCC ក្នុងឆ្នាំ២០២៥ មានជនរងគ្រោះចំនួន២១៦នាក់ស្នើសុំជំនួយផ្នែកច្បាប់ដែលករណីរបស់ពួកគេត្រូវបានបញ្ជូនទៅកាន់តុលាការរាជធានីនិងខេត្ត ។ ជាលទ្ធផលឆ្នាំ២០២៥ មាន១៣៧ករណីត្រូវបានបញ្ចប់តាមដំណើរការផ្លូវច្បាប់របស់តុលាការ ។ ក្នុងចំណោមទាំង១៣៧ ករណីនោះ មាន៦១ករណីដែលជនប្រព្រឹត្តបទល្មើសត្រូវកាត់ទោសអោយជាប់ពន្ធធានាគារ (៥៩ករណីជាករណីរំលោភបំពានផ្លូវភេទ និង២ករណីជាករណីអំពើហិង្សាក្នុងគ្រួសារ)។

### ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលដាក់ពាក្យបណ្តឹងទៅតុលាការ ឆ្នាំ២០២៥

| ករណី | ករណីក្រោមអាយុ១៨ឆ្នាំ | | | | | ករណីលើអាយុ១៨ឆ្នាំ | | | | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | ក.ធ | **សរុប** | ភ.ព | ប.ជ | ស.រ | ក.ធ | **សរុប** | |
| អំពើហិង្សាក្នុងគ្រួសារ | ០ | ០ | ០ | ០ | ០ | ២២ | ៦ | ៨៧ | ២៤ | ១៣៩ | ១៣៩ |
| រំលោភបំពានផ្លូវភេទ | ១៣ | ២៣ | ១៧ | ១៧ | ៧០ | ០ | ១ | ១ | ៤ | ៦ | ៧៦ |
| ការជួញដូរមនុស្ស | ០ | ០ | ០ | ០ | ០ | ០ | ១ | ០ | ០ | ១ | ១ |
| **សរុប** | **១៣** | **២៣** | **១៧** | **១៧** | **៧០** | **២២** | **៨** | **៨៨** | **២៨** | **១៤៦** | **២១៦** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

### ទិន្នន័យករណីអំពើហិង្សាទាក់ទងយេឌ័រដែលបានជំនុំជម្រះ ឆ្នាំ២០២៥

| ករណី | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ១៩ | ០ | ៥៥ | ១ | ៧៥ |
| រំលោភបំពានផ្លូវភេទ | ៩ | ១២ | ២៣ | ១៨ | ៦២ |
| ការជួញដូរមនុស្ស | ០ | ០ | ០ | ០ | ០ |

| សរុប | ២៨ | ១២ | ៧៨ | ១៩ | ១៣៧ |
|---|---|---|---|---|---|

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

**ទិន្នន័យជនប្រព្រឹត្តបទល្មើសដែលបានបញ្ជូនទៅកាន់ពន្ធធានាគា ឆ្នាំ២០២៥**

| ករណី | ភ.ព | ប.ជ | ស.រ | ក.ធ | សរុប |
|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ០ | ០ | ១ | ១ | **២** |
| រំលោភបំពានផ្លូវភេទ | ៩ | ១៦ | ២៣ | ១១ | **៥៩** |
| ការជួញដូរមនុស្ស | ០ | ០ | ០ | ០ | **០** |
| សរុប | **៩** | **១៦** | **២៤** | **១២** | **៦១** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

## ២.៣ មណ្ឌលសុវត្ថិភាព

អតិថិជនដែលបានស្នាក់នៅក្នុងមណ្ឌលសុវត្ថាពរបស់អង្គការ CWCC ក្នុងរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាបក្នុងឆ្នាំ២០២៥ មានចំនួនសរុប៣១៧នាក់ (ដែលក្នុងនោះមានជនរងគ្រោះ ២៦០នាក់ និងសាច់ញាត្តិ៥៧នាក់)។ ក្នុងចំណោមពួកគេទាំងអស់ មានអតិថិជនអាយុក្រោម១៨ឆ្នាំ ចំនួន២០៣នាក់ (១០១នាក់ជាជនរងគ្រោះ និង ៣០នាក់ជាសាច់ញាត្តិ)។ ក្នុងកំឡុងពេលនៃ ការស្នាក់នៅក្នុងមណ្ឌលសុវត្ថិភាពជនរងគ្រោះទទួលបានការប្រឹក្សាជាបុគ្គលនិងជាក្រុម ដើម្បីកសាងទំនុក ចិត្តនិងភាពជឿជាក់លើខ្លួនឯង។ អតិថិជនក៏ទទួលបានវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដូចជាជំនាញ កាត់ដេរ ចំអិនម្ហូប និងថ្នាក់អក្ខរកម្មផងដែរ ។ បន្ថែមពីនេះទៅទៀត អតិថិជនដែលមិនទាន់គ្រប់អាយុ បានបញ្ជូនអោយទៅសិក្សានៅសាលារដ្ឋដែលនៅជិតមណ្ឌល ហើយកុមារតូចៗដែលមានអាយុក្រោម៥ឆ្នាំទទួលបាន សេវាថែទាំប្រចាំថ្ងៃ។

**ចំនួនជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌល់សុវត្ថិភាពអង្គការ CWCC ឆ្នាំ២០២៥**

| ជនរងគ្រោះ | អាយុក្រោម ១៨ឆ្នាំ | | | | អាយុលើ ១៨ឆ្នាំ | | | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | សរុប | ភ.ព | ប.ជ | ស.រ | សរុប | |
| អំពើហិង្សាក្នុងគ្រួសារ | ០ | ៥ | ៨ | **១៣** | ៣ | ៨ | ១៣ | **២៤** | **៣៧** |
| រំលោភបំពានផ្លូវភេទ | ៣ | ៦ | ១១ | **២០** | ០ | ១ | ១ | **២** | **២២** |
| ការជួញដូរមនុស្ស | ៥២ | ៣ | ១ | **៥៦** | ១០០ | ៥ | ០ | **១០៥** | **១៦១** |
| ពលករចំណាកស្រុក | ០ | ១២ | ០ | **១២** | ០ | ២៨ | ០ | **២៨** | **៤០** |
| **សរុប** | **៥៥** | **២៦** | **២០** | **១០១** | **១០៣** | **៤២** | **១៤** | **១៥៩** | **២៦០** |

| សាច់ញាត្តិ | អាយុក្រោម ១៨ឆ្នាំ | | | | អាយុលើ ១៨ឆ្នាំ | | | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|
| | ភ.ព | ប.ជ | ស.រ | សរុប | ភ.ព | ប.ជ | ស.រ | សរុប | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ៣ | ១០ | ៦ | **១៩** | ១ | ២ | ៨ | **១១** | **៣០** |
| រំលោភបំពានផ្លូវភេទ | ០ | ២ | ៧ | **៩** | ០ | ២ | ១២ | **១៤** | **២៣** |
| ការជួញដូរមនុស្ស | ២ | ០ | ០ | **២** | ២ | ០ | ០ | **២** | **៤** |
| **សរុប** | **៥** | **១២** | **១៣** | **៣០** | **៣** | **៤** | **២០** | **២៧** | **៥៧** |
| **សរុបរួម** | **៦០** | **៣៨** | **៣៣** | **១៣១** | **១០៦** | **៤៦** | **៣៤** | **១៨៦** | **៣១៧** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប*

### ២.៤ គម្រោងសមាហរណកម្ម

ក្នុងឆ្នាំ២០២៥ បន្ទាប់ពីករណីរបស់ជនរងគ្រោះត្រូវបានបញ្ចប់នៅតុលាការ និងស្នាក់នៅមណ្ឌល មានជនរងគ្រោះចំនួន៨៩នាក់និងសាច់ញាត្តិចំនួន១១នាក់ ត្រូវបានធ្វើសមាហរណកម្មទៅតាមសហគមន៍ ដែលពួកគេជ្រើសរើស។ ក្នុងចំណោមជនរងគ្រោះទាំងអស់ មានជនរងគ្រោះចំនួន៧០នាក់ ទទួលបានជំនួយឧបត្ថម្ភគាំទ្រជាថវិកា និងសម្ភារៈសម្រាប់ការរស់នៅ ហើយមានជនរងគ្រោះចំនួន៤នាក់ទទួលបានជំនួយឧបត្ថម្ភគាំទ្រការធ្វើអាជីវកម្ម ដើម្បីធានាអោយបានការរស់នៅប្រកបដោយ ឯករាជ្យ និងនិរន្តរភាព ហើយចៀសផុតពីអំពើហឹង្សា និងបរិយាកាសងាយរងគ្រោះណាមួយ។ បុគ្គលិកគម្រោងនៅតែបន្ត តាមដានស្ថានភាពរបស់អតិថិជន ដែលបានធ្វើសមាហរណកម្ម តាមរយៈការធ្វើទំនាក់ទំនងជាមួយអាជ្ញាធរក្នុងតំបន់ ការសួរសុខទុក្ខនៅផ្ទះអតិថិជន ដើម្បីធ្វើអោយប្រាកដបាននូវការធ្វើសមាហរណកម្មមានភាពជោគជ័យ ។

**ចំនួនអតិថិជនដែលបានធ្វើសមាហរណកម្មឆ្នាំ ២០២៥**

| **ករណី** | ជនរងគ្រោះ | | | | | សាច់ញាត្តិ | | | | | **សរុបរួម** |
|---|---|---|---|---|---|---|---|---|---|---|---|
| | **ភ.ព** | **ប.ជ** | **ស.រ** | **ក.ធ** | **សរុប** | **ភ.ព** | **ប.ជ** | **ស.រ** | **ក.ធ** | **សរុប** | |
| អំពើហិង្សាក្នុងគ្រួសារ | ០ | ២ | ១០ | ៧ | **១៩** | ០ | ៣ | ៥ | ៥ | **៨** | **២៧** |
| រំលោភបំពានផ្លូវភេទ | ២ | ៣ | ៤ | ១៨ | **២៧** | ០ | ១ | ២ | ២៩ | **៣** | **៣០** |
| ការជួញដូរមនុស្ស | ៤២ | ០ | ១ | ០ | **៤៣** | ០ | ០ | ០ | ០ | **០** | **៤៣** |
| **សរុប** | **៤៤** | **៥** | **១៥** | **២៥** | **៨៩** | **០** | **៤** | **៧** | **៣៤** | **១១** | **១០០** |

*ចំណាំ៖ ភ.ព=ភ្នំពេញ ប.ជ=បន្ទាយមានជ័យ ស.រ=សៀមរាប ក.ធ=កំពង់ធំ*

## ៣. កម្មវិធីស្វែងរកមតិគាំទ្រ

### ៣.១ ការសហការណ៍ជាមួយរាជរដ្ឋាភិបាល

មន្ត្រីអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមកិច្ចប្រជុំដៃគូ GBV នៅថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០២៥ ដែលបានពង្រឹងការសម្របសម្រួលអន្តរទីភ្នាក់ងារបង្កើនចំណេះដឹងបច្ចេកទេស និងលើកកម្ពស់ការឆ្លើយតប GBV។ កិច្ចប្រជុំ នេះបានអនុញ្ញាតឱ្យរដ្ឋាភិបាល និងដៃគូអង្គការមិនមែនរដ្ឋាភិបាលចែករំលែក បច្ចុប្បន្នភាព សំខាន់ៗ ដោះស្រាយ គម្លាតសេវាកម្ម និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែង រួមទាំង NAPVAW, GBV Safe App mapping និង ហានិភ័យទាក់ទងនឹងអាកាសធាតុ។ ទោះបីជាមានឧបសគ្គ

ថវិកាក៏ដោយ ដៃគូបានប្តេជ្ញាចិត្តក្នុងការ ពង្រីកសេវាកម្មប្រកបដោយគុណភាព និងសហការអភិវឌ្ឍគំនិតផ្តួចផ្តើមការទប់ស្កាត់ GBV ដោយប្រើក្របខ័ណ្ឌ RESPECT ។ កិច្ចប្រជុំនេះបានពង្រឹងកិច្ចសហប្រតិបត្តិការ និងកំណត់ទិសដៅច្បាស់លាស់សម្រាប់កម្មវិធី GBV ប្រកបដោយបរិយាប័ន្ន និងផ្តោតលើអ្នករស់រានមានជីវិតនៅកម្ពុជា។

មន្ត្រីអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមកិច្ចប្រជុំកិច្ចប្រជុំលើកទី២ របស់គណៈកម្មាធិការសម្របសម្រួលខេត្ត (PCC) ក្រោមកម្មវិធី ACCESS 2 បានជួយពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗ តាមរយៈការចែករំលែកជាផ្លូវការនូវអនុក្រឹត្យលេខ 191/24 SSR ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥ ដែលអនុម័តដោយអភិបាលខេត្ត។ អនុក្រឹត្យនេះកំណត់រចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់ PCC និងបញ្ជាក់ជាថ្មីអំពីតួនាទីសម្របសម្រួលរបស់ខ្លួនក្នុងការកែលម្អសេវាកម្មសម្រាប់អ្នករស់រានមានជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រ (GBV) ជនមានពិការភាព និងបុគ្គលដែលត្រូវការស្តារនីតិសម្បទា។ បុគ្គលិកគម្រោង អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមក្នុងកិច្ចប្រជុំ និងរួមចំណែកយ៉ាងសកម្មក្នុងការពិភាក្សា ជាពិសេសលើបញ្ហាទាក់ទងនឹង GBV និងការរួមបញ្ចូលពិការភាព។

នៅខែមេសា ឆ្នាំ ២០២៥ បុគ្គលិក អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមក្នុងកិច្ចប្រជុំប្រចាំត្រីមាសGBV ខេត្ត ដែលមានភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីពិនិត្យមើលសមិទ្ធផល ដោះស្រាយបញ្ហាប្រឈម និងបង្កើត ផែនការសម្រាប់ត្រីមាសបន្ទាប់។ កិច្ចប្រជុំនេះបានផ្តល់វេទិកាដ៏សំខាន់មួយដើម្បីពិភាក្សាអំពីកិច្ចខិតខំប្រឹងប្រែង អន្តរាគមន៍ និងពង្រឹងតម្រូវការក្នុងការធានាសេវាកម្មប្រកបដោយគុណភាពសម្រាប់អ្នករស់រានមានជីវិត។ ស្រុកទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យប្រើឧបករណ៍ត្រួតពិនិត្យការពេញចិត្ត ដែលប្រមូលមតិយោបល់ពី អ្នករស់រានមាន ជីវិត។ មតិយោបល់ទាំងនេះបម្រើជាធាតុចូលដ៏មានតម្លៃដើម្បីកែលម្អការផ្តល់សេវា និងបំពេញតម្រូវការរបស់អ្នករស់ រានមានជីវិតឱ្យកាន់តែប្រសើរឡើង។

នៅខែមិថុនា ឆ្នាំ ២០២៥ បុគ្គលិក អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមកិច្ចប្រជុំប្រចាំត្រីមាស GBV ខេត្ត ដើម្បីពិនិត្យមើលសមិទ្ធផល បញ្ហាប្រឈម និងសកម្មភាពដើម្បីឆ្លើយតបកាន់តែប្រសើរឡើងចំពោះ តម្រូវការរបស់ស្ត្រី និងក្មេងស្រី។ កិច្ចប្រជុំនេះមានគោលបំណងពង្រឹងគុណភាពសេវាកម្មសម្រាប់អ្នករស់រានមាន ជីវិត។

បុគ្គលិកគម្រោង អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំសម្របសម្រួលស្តីពីការបញ្ចប់ផែនការសកម្មភាពប្រចាំឆ្នាំខេត្តសម្រាប់ការឆ្លើយតបទៅនឹងអំពើហិង្សាលើយេនឌ័រ (GBV) និងការរៀបចំផែនការលទ្ធផលប្រចាំឆមាសប្រចាំឆ្នាំ GBV សម្រាប់ដាក់ជូនគណៈកម្មាធិការសម្របសម្រួលខេត្ត (PCC)។ កិច្ចប្រជុំបានរួមចំណែកដល់ការបញ្ចប់ផែនការឆ្លើយតប GBV ប្រចាំឆ្នាំ ដោយមានការគាំទ្រពី ACCESS 2 ការរៀបចំផែនការថវិកាជាមួយសកម្មភាពខេត្ត និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងមន្ទីរកិច្ចការនារី និងដៃគូពាក់ព័ន្ធ។

### ៣.២ ការងារជាបណ្តាញ

អង្គការ CWCC បានចូលរួមក្នុងកិច្ចប្រជុំ GBV ដឹកនាំដោយ UNFPA នៅថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ ២០២៥។ ការធ្វើបច្ចុប្បន្នភាព និងសកម្មភាពសំខាន់ៗត្រូវបានពិភាក្សាទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងស្តីពីអំពើហិង្សា ទាក់ទងយេនឌ័រនៅក្នុងប្រទេសកម្ពុជា។ ធនាគារពិភពលោកបានបង្ហាញគម្រោងផែនទីសេវាកម្ម

GBV រយៈពេលពីរឆ្នាំរបស់ពួកគេ ដែលកំណត់គោលដៅ ២៥ ខេត្តដើម្បីកំណត់គម្លាតនៃសេវាកម្ម និងវាយតម្លៃលទ្ធភាពប្រើប្រាស់។ UN Women បានធ្វើបច្ចុប្បន្នភាពលើការអភិវឌ្ឍន៍ NAP-VAW លើកទី ៤ ហើយបានប្រកាសសិក្ខាសាលាពិគ្រោះយោបល់ដែលគ្រោងធ្វើនៅខែតុលា។ អង្គការ CARE បានពិភាក្សាអំពីផលប៉ះពាល់សេដ្ឋកិច្ចរបស់ GBV នៅក្នុងវិស័យកាត់ដេរ និងបានតស៊ូមតិសម្រាប់ការអនុវត្តច្បាប់ GBVH កាន់តែប្រសើរ។ អង្គការយូនីសេហ្វបានចែករំលែក SOP ការការពារកុមាររបស់ពួកគេ ដោយផ្តោតលើការកសាងសមត្ថភាព និងស្តង់ដារនៃប្រព័ន្ធការពារកុមារ។ ADB បានគូសបញ្ជាក់ពីគម្រោងផ្តល់ជំនួយចំនួន ១០ លានដុល្លារ ក្នុងគោលបំណងពង្រឹងប្រព័ន្ធឆ្លើយតប GBV នៅកម្ពុជា។ កិច្ចប្រជុំបានបញ្ចប់ជា មួយនឹងផែនការសម្រាប់ការពិគ្រោះយោបល់ និងសកម្មភាពនាពេលអនាគត រួមទាំងការធ្វើបច្ចុប្បន្នភាពលើការគ្រប់គ្រងករណី GBV និងការអនុវត្តល្អ។

បុគ្គលិកវាយតម្លៃគម្រោង (M&E) បានចូលរួមក្នុងសិក្ខាសាលាដើម្បីពិនិត្យនិងចុងក្រោយសេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិ ៥ ឆ្នាំ (២០២៥-២០២៨) ស្តីពីការប្រយុទ្ធនឹងការជួញដូរមនុស្ស។ សិក្ខាសាលានេះបាន ប្រារព្ធឡើងនៅក្រសួងមហាផ្ទៃ និងដឹកនាំដោយលោកជំទាវ ជូ ប៊ុន អេង រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ និងអនុប្រធានអចិន្ត្រៃយ៍ ។

បុគ្គលិកគម្រោងបានចូលរួមក្នុងការបណ្តុះបណ្តាលអ្នកបណ្តុះបណ្តាល (TOT) ស្តីពីការរួមបញ្ចូល និងការតាមដានជនរងគ្រោះនៃការជួញដូរមនុស្ស និងការរំលោភផ្លូវភេទនៅក្នុងមណ្ឌលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ដែលមានឥទ្ធិពលសំខាន់លើគម្រោង ដែលរៀបចំឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា។ មន្ត្រីផ្នែកការរួមបញ្ចូលបានទទួលជំនាញ និងចំណេះដឹងសំខាន់ដើម្បីគាំទ្រ និងរួមបញ្ចូលជនរងគ្រោះបានល្អប្រសើរជាងមុន។ ការបណ្តុះបណ្តាលនេះ បានពង្រឹងការសហការរវាងភាគីពាក់ព័ន្ធផ្សេងៗដោយនាំទៅរកប្រព័ន្ធតាមដាន និងគាំទ្រដែលមានប្រសិទ្ធភាព ជាងមុន។

បុគ្គលិកគម្រោងបានចូលរួមកម្មវិធីពិភាក្សាពិគ្រោះយោបល់ និងកិច្ចប្រជុំ ថ្នាក់តំបន់តាមរយៈ Zoom សម្រាប់គម្រោង "ការធានានូវការងារសមរម្យ និងកាត់បន្ថយភាពងាយរងគ្រោះសម្រាប់ស្ត្រី និងកុមារក្នុងបរិបទនៃការធ្វើចំណាកស្រុកការងារនៅអាស៊ីអាគ្នេយ៍" (PROTECT) មានគោលបំណងដោះស្រាយបញ្ហាប្រឈមរបស់ស្ត្រីនិងកុមារនៅក្នុងតំបន់ ដោយផ្តោតលើការលើកកម្ពស់ការអនុវត្តការងារប្រកបដោយសុវត្ថិភាព និងយុត្តិធម៌ កាត់បន្ថយភាពងាយរងគ្រោះ និងការលើកកម្ពស់ប្រព័ន្ធគាំទ្រសម្រាប់គ្រួសារចំណាកស្រុក។ កិច្ចសន្ទនាបានប្រមូលផ្តុំភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងអ្នកបង្កើតគោលនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងអ្នកដឹកនាំសហគមន៍ ដើម្បីពិភាក្សាអំពីយុទ្ធសាស្រ្ត និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាសម្រាប់ការអនុវត្តគោលដៅរបស់គម្រោងប្រកបដោយប្រសិទ្ធភាព។

### ៣.៣ យុទ្ធនាការស្វែងរកមតិគាំទ្រ

បុគ្គលិកគម្រោងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានចូលរួមក្នុងកិច្ចប្រជុំដៃគូ GBV និងរួមចំណែកក្នុងការពិភាក្សាអំពីការការពារ GBV ក្នុងគ្រាអាសន្ន ការធ្វើបច្ចុប្បន្នភាព NAPVAW និងការការពារពលករ ចំណាកស្រុកវិលត្រឡប់តាមព្រំដែន។ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ បានចែករំលែកការគាំទ្រជាបន្ត បន្ទាប់សម្រាប់ជនចំណាកស្រុកដែលត្រឡប់មកវិញនៅខេត្តកំពង់ស្ពឺ និងសៀមរាប រួមទាំងការប្រឹក្សាយោបល់ និងការគាំទ្រស្វែងរកការងារតាមរយៈ Telegram ។ កិច្ចប្រជុំនេះបានពង្រឹងការ សម្របសម្រួល

ជាមួយទីភ្នាក់ងារ អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើគំរូការពារ GBV ការសម្របសម្រួលយេនឌ័រ និងការសម្របសម្រួលដោយបច្ចេកវិទ្យា និងជួយសម្របសម្រួលអន្តរាគមន៍ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ជាមួយគំនិតផ្តួចផ្តើមថ្នាក់ជាតិ និងតំបន់។

បុគ្គលិកគម្រោងអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ និងដៃគូបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់គណៈកម្មាធិការសម្របសម្រួលខេត្តនៅខេត្តកំពង់ធំ ដើម្បីពង្រឹងសមាហរណកម្មសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ទៅក្នុងកម្មវិធីវិនិយោគថ្នាក់ក្រោមជាតិ។ កិច្ចប្រជុំនេះមានអ្នកចូលរួមចំនួន 43 នាក់មកពីមន្ទីរខេត្ត ស្រុក និងដៃគូអនុវត្តយុទ្ធសាស្ត្រ។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ សហការជាមួយក្រុមការងារអំពើហិង្សាផ្អែកលើយេនឌ័រ (GBV) នៃស្រុកបសេដ្ឋ ខេត្តកមពង់ស្ពឺ និង ស្រុកក្រឡាញ់ ខេត្តសៀមរាប បានរៀបចំ និងដឹកនាំសកម្មភាពយុទ្ធនាការ ១៦ ថ្ងៃដើម្បីបញ្ចប់អំពើហិង្សាដែលសម្របសម្រួលដោយបច្ចេកវិទ្យាឌីជីថលប្រឆាំងនឹងស្ត្រី និងក្មេងស្រីក្រោមប្រធានបទ "រួមគ្នាបញ្ឈប់អំពើហិង្សាឌីជីថលប្រឆាំងនឹងស្ត្រី និងក្មេងស្រី"។ ព្រឹត្តិការណ៍នេះមានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីយុទ្ធនាការ16ថ្ងៃ និងការការពារពលករចំណាកស្រុកដែលត្រឡប់មកវិញ និងអ្នករស់រានមានជីវិត ពីអំពើហិង្សាផ្អែកលើយេនឌ័ររួមជាមួយការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗដើម្បីលើក កម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សមភាពយេនឌ័រ និងការការពារពីអំពើហិង្សាផ្អែកលើយេនឌ័រ គ្រប់ទម្រង់ រួមទាំងអំពើហិង្សាដែលសម្របសម្រួលដោយបច្ចេកវិទ្យា។

អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ សហការជាមួយក្រុមការងារអំពើហិង្សាផ្អែកលើយេនឌ័រ (GBV) ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ និងស្រុកស្វាយលើ ខេត្តសៀមរាប ក្នុងការរៀបចំទិវានារីអន្តរជាតិឆ្នាំ ២០២៥ ក្រោមប្រធានបទ "សិទ្ធិ សមភាព និងការពង្រឹងសិទ្ធិអំណាចសម្រាប់ស្ត្រី និងក្មេងស្រីទាំងអស់។" ដោយមានការចូលរួមចូលរួមពីអាជ្ញាធរមូលដ្ឋាន សមាជិកសហគមន៍ និងយុវជន ដែលនាំឱ្យមានការចូលរួមក្នុងការលើកកម្ពស់ សមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចរបស់ស្ត្រី។ រួមគ្នាកិច្ចខិតខំប្រឹងប្រែងរួមគ្នាទាំងនេះបានពង្រឹងការ ចូលរួមរបស់សហគមន៍ លើកកម្ពស់ការយល់ដឹងអំពី GBV និងជំរុញការប្តេជ្ញាចិត្តចំពោះសមភាពយេនឌ័រ និងការគាំទ្រ អ្នករស់រានមានជីវិត។

## ៤. កម្មវិធីអភិវឌ្ឍន៍អង្គការ

### ៤.១ នាយកក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានប្រាំរូប ដែលជាអ្នកដឹកនាំអង្គការសិទ្ធិមនុស្សដ៏លេចធ្លោនៅកម្ពុជា៖ (១) ប្រធានក្រុមប្រឹក្សាភិបាល លោកមេធាវី សុក សំអឿន ជានាយកប្រតិបត្តិនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ដែលជាអង្គការជំនួយផ្នែក ច្បាប់ដ៏លេចធ្លោនៅក្នុង ប្រទេសកម្ពុជា (២) លោកស្រី លឹម ស៊ាវហុង ជាទីប្រឹក្សានៃអង្គការ Give2Asia ប្រចាំប្រទេសកម្ពុជា (៣) លោក ជា ពីដែន គឺជានាយកប្រតិបត្តិអង្គការគាំពារកុមារងាយទទួលរងគ្រោះ (VCAO) ដែលធ្វើការការពារសិទ្ធិកុមារ និងលើកកម្ពស់ការចូលរួមរបស់កុមារ (៤) លោកស្រី ប៉ែន មនោរម្យ ដែលបច្ចុប្បន្នជា នាយិការរងអង្គការ PSI និង (៥) លោកស្រី កុយ ផល្លានី ជានាយិកាប្រតិបត្តិនៃអង្គការខេមរា។

**៤.២ បុគ្គលិករបស់អង្គការ**

ក្នុងឆ្នាំ២០២៥ បុគ្គលិកអង្គការ CWCC សរុបមានបុគ្គលិកសរុបចំនួន៤៧នាក់ (បុរស១៤នាក់) ក្នុងនោះ មានបុគ្គលិកដែលមានពិការភាពចំនួន៣នាក់ (១នាក់ជាបុរស)។ បុគ្គលិកនៅការិយាល័យភ្នំពេញ ១៩នាក់ (ស្រី១៤នាក់) ការិយល័យខេត្តសៀមរាបមាន១៣នាក់ (ស្រី៩នាក់) ការិយាល័យខេត្តបន្ទាយមានជ័យមាន ៧នាក់ (ស្រី៤នាក់) ការិយាល័យខេត្តកំពង់ធំមាន៦នាក់ (ស្រី៤នាក់)។

**៤.៣ ការកសាងសមត្ថភាពបុគ្គលិក**

បុគ្គលិកអង្គការ CWCC បានទទួលការបបណ្តុះបណ្តាលដើម្បីលើកកម្ពស់សមត្ថភាពការងារ និងអភិវឌ្ឍបុគ្គលិកឆ្នាំ២០២៥ មានដូចជា៖

១. វគ្គបណ្តុះបណ្តាលអំពី "ការការពារកុមារ ការពារសុវត្ថិភាព និងការបញ្ជៀបយេនឌ័រ" រៀបចំដោយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ កាលពីថ្ងៃទី១៥ - ១៦ ខែមករា ឆ្នាំ២០២៥ នៅសណ្ឋាគារអង្គរហូលីដេ ខេត្តសៀមរាប ។

២. វគ្គបណ្តុះបណ្តាលអំពី "ការដាក់ឲ្យប្រើប្រាសនីតិប្រតិបត្តិ មាតុភូមិនិវត្តន៍ជនរងគ្រោះ និងបុគ្គលដែលសង្ស័យថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស " រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីថ្ងៃទី៣១ ខែ មករា ឆ្នាំ២០២៥ នៅសណ្ឋាគារសាន់អេនមូន។

៣. វគ្គបណ្តុះបណ្តាលអំពី "ការថៃទាំផ្អែកលើការយល់ដឹងអំពីរបួសផ្លូវចិត្តសម្រាប់កុមារ ដែលជាជនរងគ្រោះពី OSEA" រៀបចំដោយអង្គការ World Hope International កាលពីថ្ងៃទី ១១ - ១៣ ខែមីនា ឆ្នាំ២០២៥ នៅសណ្ឋាគារNovotel ។

៤. វគ្គបណ្តុះបណ្តាលអំពី "ការជ្រើសរើសបុគ្គលិកតាមសីលធម៌១០១" រៀបចំដោយវិទ្យាស្ថាន ISSARA កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៥ តាមបណ្តាញអ៊ីនធឺណែត។

៥. វគ្គបណ្តុះបណ្តាលអំពី "ការធ្វើបច្ចុប្បន្នភាពបទដ្ឋានអប្បបរមា សម្រាប់ការថៃទាំជនរងគ្រោះដោយការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ស្នាក់នៅក្នុងមណ្ឌល" រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៥ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

៦. វគ្គបណ្តុះបណ្តាលអំពី "សន្តិសុខសាយប័រ (Cyber Security)" រៀបចំដោយអង្គការ UNWOMEN កាលពី ថ្ងៃទី04-05 ខែ មិថុនា ឆ្នាំ២០២៥ នៅសណ្ឋាគារNovotel ។

៧. វគ្គបណ្តុះបណ្តាលអំពី "ទម្រង់របាយការណ៍ និងឧបករណ៍ប្រមូលទិន្នន័យ សម្រាប់ការផ្តល់សេវាការពារ ដល់ជនរងគ្រោះពីការជួញដូរមនុស្ស និងការប្រើប្រាស់ផ្លូវភេទ" រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

៨. វគ្គបណ្តុះបណ្តាលអំពី "កិច្ចការពារកុមារ និងការការពារសុវត្ថិភាព" រៀបចំដោយអង្គការ PLAN International Cambodia កាលពីថ្ងៃទី ១៨ - ១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសណ្ឋាគារសាន់វ៉េ។

៩. ចូលរួមសិក្ខាសាលា ស្តីអំពី "បែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូមនុស្ស ដើម្បីផ្តលសេវាសមស្រប" រៀបចំដោយក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០២៥ នៅសណ្ឋាគារភ្នំពេញ។

# ៥. របាយការណ៍ហិរញ្ញវត្ថុសង្ខេប

## ៥.១ ថវិកាហិរញ្ញវត្ថុ ២០២៥

| ម្ចាស់មូលនិធិ | ថវិកា | ភាគរយ |
|---|---:|---:|
| Lotus Outreach | 123,846 | 15.97% |
| AOP | 25,636 | 3.31% |
| TDH-BMZ | 96,060 | 12.39% |
| FWC | 7,985 | 1.03% |
| ILO-Protect | 52,300 | 6.75% |
| SOLIDAR | 90,119 | 11.62% |
| ACCESS 2 | 126,976 | 16.38% |
| Rotary Club | 43,418 | 5.60% |
| UNTF | 139,110 | 17.94% |
| UN Women Protect | 30,786 | 3.97% |
| SKO | 10,978 | 1.42% |
| Professional fee, Training fee | 28,117 | 3.63% |
| **Grand Total** | **775,331** | **100.00%** |

## ៥.២ ការចំណាយហិរញ្ញវត្ថុ ២០២៥

| កម្មវិធី | ការចំណាយ | ភាគរយ |
|---|---:|---:|
| កម្មវិធីការពារ | 281,159 | 36% |
| កម្មវិធីបង្ការទប់ស្កាត់ | 293,015 | 38% |
| កម្មវិធីស្វែងរកមតិគាំទ្រ | 138,086 | 18% |
| កម្មវិធីអភិវឌ្ឍអង្គការ | 60,987 | 8% |
| **សរុប** | 773,247 | 100% |

## ៥.៣ ព័ត៌មានអំពីគណនីធនាគារ របស់អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ

បច្ចុប្បន្នអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ មានគណនីចំនួនសរុប ប្រាំមួយ ប្រាំនៅធនាគារ **អេស៊ីលីដា ភីអិលស៊ី** និង មួយទៀតនៅធនាគារ **ពាណិកម្មក្រៅប្រទេសនៃកម្ពុជា** សំរាប់ទទួលជំនួយ និងទូទាត់ចំណាយផ្សេងៗ ក្នុងការប្រតិបត្តិការគម្រោងរបស់អង្គការទាំងមូល។ គណនីទាំនេះមានឈ្មោះ និង លេខគណនីដូចខាងក្រោម៖

**ធនាគារអេស៊ីលីដា ភីអិលស៊ី ( ACLEDA Plc Bank)**

១- គណនីឈ្មោះ **CWCC UNTF**

លេខគណនី ៣៦០០-០៤៦៩១១៨៦-១៦

បច្ចុប្បន្នភាព ១៣ ខែ កុម្ភៈឆ្នាំ ២០២៥

២- គណនីឈ្មោះ **CWCC-ACCESS**

លេខគណនី ២៩០០-០៥១៨៥៣៥៨-១៨

បច្ចុប្បន្នភាព ១៣ ខែ កុម្ភៈឆ្នាំ ២០២៥

៣- គណនីឈ្មោះ **CWCC-TDH-BMZ**

លេខគណនី ២៩០០-០៥១៥៦២៤០-១០

បច្ចុប្បន្នភាព ១៣ ខែ កុម្ភៈឆ្នាំ ២០២៥

៤- គណនីឈ្មោះ **CWCC-Re**

លេខគណនី ២៩០០-២០៦៤២៤៧-១៧

បច្ចុប្បន្នភាព ១៣ ខែ កុម្ភៈឆ្នាំ ២០២៥

៥- គណនីឈ្មោះ **CWCC-HO**

លេខគណនី ២៩០០-១០៧៨៧៨៧៥-១៥

បច្ចុប្បន្នភាព ១៣ ខែ កុម្ភៈឆ្នាំ ២០២៥

**ធនាគារ ពាណិកម្មក្រៅប្រទេស នៃកម្ពុជា (FTB Bank)**

១- គណនីឈ្មោះ **CWCC-LO**

លេខគណនី ៣០០០០៤៦១៥៤៣៧

បច្ចុប្បន្នភាព ១៣ ខែ កុម្ភៈឆ្នាំ ២០២៥

## ទំនាក់ទំនង៖

### ការិយាល័យកណ្ដាលនិងរាជធានីភ្នំពេញ

- អាសយដ្ឋាន៖ #៤២F ផ្លូវ៤៨៨ ផ្សារដើមថ្កូវ ចំការមន ភ្នំពេញ កម្ពុជា
- អាសយដ្ឋានប្រៃសណីយ៖ P.O Box ២៤២១ និង CCC box ៣៥៦
- ទូរស័ព្ទ៖ (៨៥៥-២៣) ៩៨៧១៥៨/០១២ ២៤៣ ៩៨៨
- អ៊ីម៉ែល៖ PNPadmin@cwcc.org.kh PNPmanager@cwcc.org.kh

### ការិយាល័យខេត្តបន្ទាយមានជ័យ

- អាសយដ្ឋាន៖ ភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត
- ទូរស័ព្ទ ៖ (៨៥៥-៥៤) ៩៦៧ ១៩៤/០៨៧ ៩០៩០ ២០
- អ៊ីម៉ែល៖ BMCadmin@cwcc.org.kh BMCmanager@cwcc.org.kh

### ការិយាល័យខេត្តសៀមរាប

- អាសយដ្ឋាន៖ ភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប
- ទូរស័ព្ទ៖ (៨៥៥-៦៣) ៩៦៣២៧៦/០៩២ ៣៥ ២៤ ២៩
- អ៊ីម៉ែល៖ SRPadmin@cwcc.org.kh SRPmanager@cwcc.org.kh

### ការិយាល័យខេត្តកំពង់ធំ

- អាសយដ្ឋាន៖ ផ្លូវលេខ ៨ ភូមិដំរីជាន់ខ្លា សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
- ទូរស័ព្ទ៖ (៨៥៥-៦២) ២១០៥១៥/០១៧ ៤៧ ០០ ៨៦
- អ៊ីម៉ែល៖ KPTadmin@cwcc.org.kh KPTmanager@cwcc.org.kh